# ខ និង លក្ខខណ្ឌ នៃការប្រើប្រាស់កាត

# ខ និង លក្ខខណ្ឌ នៃការប្រើប្រាស់កាត

ខ និងលក្ខខណ្ឌនេះគ្រប់គ្រងការចេញ និងការប្រើប្រាស់រាល់កាតទាំងអស់ដែលចេញឲ្យប្រើដោយធនាគារ ABA។ សូមអាន ខ និង លក្ខខណ្ឌ ឲ្យបានយល់ច្បាស់។ អ្នកប្រើប្រាស់កាតទាំងអស់ត្រូវចាត់ទុកថាបានយល់ព្រមទទួលយក ខ និងលក្ខខណ្ឌនេះដោយឥតលក្ខខណ្ឌ ហើយត្រូវគោរពនូវ ខ និងលក្ខខណ្ឌទាំងនេះក្រោយពេលទទួលបានកាតដែលចេញដោយធនាគារ ABA។ អ្នកប្រើប្រាស់កាតទាំងអស់ក៏ត្រូវបានចាត់ទុកថា បានយល់ព្រមទទួលយករាល់វិសោធនកម្មទាំងអស់លើ ខ និងលក្ខខណ្ឌទាំងនេះដែលធ្វើឡើងដោយធនាគារ ABA យោងទៅតាមខ និងលក្ខខណ្ឌនេះ។

## 1. និយមន័យ

**ធនាគារ** ABA សំដៅលើ ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់។

**អេ ធី អឹម** សំដៅលើ ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ដោយមធ្យោបាយដែលអ្នកប្រើប្រាស់កាតអាចចូលគណនីដែលបានកំណត់ និងធ្វើប្រតិបត្តិការ (រួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែ ការដកប្រាក់ ឬដាក់ប្រាក់) ដោយប្រើកាតរបស់អ្នកប្រើប្រាស់។

**កាត** សំដៅលើ កាតឥណពន្ធ ឬកាតឥណទានដែលចេញដោយ ធនាគារ ABA។

**អ្នកប្រើប្រាស់កាត** សំដៅលើ អតិថិជនប្រើប្រាស់កាតដែលចេញដោយ ធនាគារ ABA។

**គណនីដែលបានកំណត់** សំដៅលើ គណនី ABA ដែលកាន់កាប់ដោយអ្នកប្រើប្រាស់កាត និងត្រូវបានភ្ជាប់ជាមួយកាត។

**ខ និងលក្ខខណ្ឌ** សំដៅលើ ខ និងលក្ខខណ្ឌ ដែលអាចនឹងត្រូវធ្វើវិសោធនកម្មពីពេលមួយទៅពេលមួយ។

**ប្រតិបត្តិការ** សំដៅលើ ប្រតិបត្តិការហិរញ្ញវត្ថុដែលធ្វើ ឬប្រតិបត្តិឡើង ដំណើរការ ឬ ធ្វើឲ្យមានប្រសិទ្ធភាព ដោយរូបអ្នក ឬបុគ្គលណាដែលអះអាងថាជារូបអ្នក ឬបុគ្គលណាដែលអះអាងថាជាអ្នកតំណាងឲ្យរូបអ្នក ដោយមាន ឬគ្មានការយល់ព្រមពីអ្នក ពាក់ព័ន្ធនឹងគណនីដែលបានកំណត់។

## 2. ថ្លៃសេវា និងកម្រៃជើងសា

ធនាគារ ABA រក្សាសិទ្ធិក្នុងការគិតថ្លៃសេវា និងកម្រៃជើងសាដែលត្រូវបង់ដោយអ្នកប្រើប្រាស់កាតចំពោះកាតដែលត្រូវបានចេញឲ្យប្រើប្រាស់ដូចដែលបានចែងនៅលើគេហទំព័ររបស់ធនាគារ ហើយមានសិទ្ធិកាត់ប្រាក់តាមចំនួននៃថ្លៃសេវា និងកម្រៃជើងសាពីគណនីដែលបានកំណត់របស់អ្នកប្រើប្រាស់ដែលបានភ្ជាប់នឹងកាតនោះ។ ធនាគារ ABA រក្សាសិទ្ធិក្នុងការកែប្រែបញ្ជីថ្លៃសេវា និងបន្ទុកដែលត្រូវកាត់ ហើយត្រូវផ្សព្វផ្សាយការកែប្រែនោះនៅលើគេហទំព័ររបស់ធនាគារ។ ការកែប្រែទាំងនោះត្រូវចូលជាធរមានមិនលើសពី៣០ ថ្ងៃក្រោយពីការផ្សព្វផ្សាយនៅលើគេហទំព័ររបស់ធនាគារ។

## 3. កាតដែលចេញឲ្យនីតិបុគ្គល

អ្នកប្រើប្រាស់កាតណាម្នាក់ដែលមិនមែនជារូបវន្តបុគ្គល (រួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែក្រុមហ៊ុន អង្គការក្រៅរដ្ឋាភិបាល សមាគម ក្រុមហ៊ុនសហកម្មសិទ្ធិ និងបរធនបាលកិច្ច) ត្រូវតែទទួលខុសត្រូវចំពោះ រាល់បំណុលទាំងអស់ដែលកើតឡើង និងប្រតិបត្តិការដែលធ្វើឡើង ដោយម្ចាស់ភាគហ៊ុន អភិបាល និយោជិត, ទីប្រឹក្សា ឬភ្នាក់ងារណាម្នាក់ដែលប្រើប្រាស់កាតនោះ។ អ្នកប្រើប្រាស់កាតត្រូវជូនដំណឹងភ្លាមៗទៅកាន់ធនាគារ ABA ប្រសិនបើមានការផ្លាស់ប្តូរណាមួយពាក់ព័ន្ធនឹង ម្ចាស់ភាគហ៊ុន ឬអភិបាល នៃនីតិបុគ្គលនោះ ឬ សេវាកម្មរបស់ និយោជិត ទីប្រឹក្សា ឬភ្នាក់ងាររបស់ខ្លួន ត្រូវបានបញ្ចប់ (ដោយទូរស័ព្ទទៅលេខ ១ ៨០០ ២០៣ ២០៣ (ដោយឥតគិតថ្លៃ)/(+៨៥៥) ៩៨ ២០៣ ៣៣៣ ឬផ្ញើសារទៅកាន់ info@ababank.com និង/ឬ customerservice@ababank.com)។

## 4. ការកំណត់លើកាត

ធនាគារ ABA រក្សាសិទ្ធិក្នុងការកំណត់ចំនួនដងនៃការដកប្រាក់ឬ ចំនួនទឹកប្រាក់ដែលដកដោយអ្នកប្រើប្រាស់កាតពីគណនីពាក់ព័ន្ធដែលបានកំណត់របស់អ្នកប្រើប្រាស់កាត ហើយកែប្រែការកំណត់នោះតាមឆន្ទានុសិទ្ធិរបស់ធនាគារពីមួយពេលទៅមួយពេល និងនៅពេលណាមួយក៏បាន។ ធនាគារ ABA នឹងជូនដំណឹងអំពីការកំណត់ទាំងនោះទៅដល់អ្នកប្រើប្រាស់កាត តាមមធ្យោបាយដែលខ្លួនយល់ថាសមស្រប ដោយធនាគារ ABA នឹងមិនទទួលខុសត្រូវណាមួយចំពោះការខកខានណាមួយក្នុងការជូនដំណឹងឡើយ។ ប៉ុន្តែការកំណត់នេះមិនត្រូវប៉ះពាល់ចំពោះសិទ្ធិរបស់អ្នកប្រើប្រាស់កាតនៅពេលដកប្រាក់ដោយផ្ទាល់នៅសាខារបស់ធនាគារ ABA ពីគណនីដែលបានកំណត់។

## 5. ការប្រើប្រាស់កាត ឬគណនីធនាគារដោយមិនស្របច្បាប់

ការប្រើប្រាស់កាត ឬគណនីធនាគារចូលក្នុងប្រតិបត្តិការដែលមិនស្របច្បាប់ ឬសម្រាប់គោលដៅមិនស្របច្បាប់ណាមួយ គឺត្រូវបានហាមឃាត់ដាច់ខាត។ ប្រសិនបើអ្នកប្រើប្រាស់កាត ឬគណនីធនាគារចូលក្នុងប្រតិបត្តិការមិនស្របច្បាប់ ឬសម្រាប់គោលដៅមិនស្របច្បាប់ ធនាគារ ABA រក្សាសិទ្ធិក្នុងការផ្អាក ឬបញ្ចប់ការប្រើប្រាស់គណនីធនាគាររបស់អ្នកប្រើប្រាស់កាត និង/ឬ ដកហូតកាតវិញដោយមិនផ្តល់មូលហេតុណាមួយឡើយ។ ការសម្រេចចិត្តរបស់ធនាគារ ABA គឺជាការសម្រេចចិត្តផ្លូវការចុងក្រោយ ហើយអ្នកប្រើប្រាស់កាតត្រូវគោរពតាម។

## 6. ប្រតិបត្តិការរបស់គណនីកាត

ការដកប្រាក់ណាមួយដែលមានក្នុងគណនីដែលបានកំណត់ ឬប្រតិបត្តិការដែលបានធ្វើដោយអ្នកប្រើប្រាស់កាត (ឬអ្នកផ្សេងក្រៅពីអ្នកប្រើប្រាស់កាត) ដោយប្រើកាតដែលពាក់ព័ន្ធដើម្បីធ្វើការបញ្ជាទិញទំនិញ ឬសេវាកម្ម ពីពាណិជ្ជករ និងស្ថាប័នផ្សេងទៀតដោយផ្ទាល់ តាមប្រៃសណីយ៍ ការបញ្ជាទិញតាមទូរស័ព្ទ ប្រព័ន្ធអនឡាញ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀត នឹងត្រូវកាត់ដោយផ្ទាល់ពីគណនីដែលបានកំណត់ ហើយធនាគារ ABA នឹងមិនមានកាតព្វកិច្ចក្នុងការសាកសួរ ឬកំណត់ថាតើអ្នកប្រើប្រាស់កាតបានផ្តួចផ្តើម បានដឹង ឬយល់ព្រមក្នុងការដកប្រាក់ ឬ ធ្វើប្រតិបត្តិការឡើយ។

## 7. កម្មសិទ្ធិលើកាត

សិទ្ធិ កម្មសិទ្ធិ និងប្រយោជន៍ ដែលមានក្នុង និងចំពោះកាតទាំងអស់ដែលចេញរួច នៅតែជា សិទ្ធិ កម្មសិទ្ធិ និងអត្ថប្រយោជន៍របស់ធនាគារ ABA ហើយអ្នកប្រើប្រាស់កាតមិនមានសិទ្ធិលើសពីសិទ្ធិប្រើប្រាស់ចំពោះកាតដែលចេញឲ្យប្រើប្រាស់នោះឡើយ។ អ្នកប្រើប្រាស់កាតមិនត្រូវកែប្រែ ធ្វើការផ្លាស់ប្តូរដែលបណ្តាលឲ្យខូច ឬអនុញ្ញាតធ្វើឲ្យមានការខូចខាតណាមួយកើតឡើងចំពោះ ឆ្នូតម៉ាញេទិក (magnetic-stripe) នៅលើកាត ឬផ្នែកផ្សេងទៀតណាមួយនៃកាតឡើយ។ អ្នកប្រើប្រាស់កាតត្រូវប្រគល់វិញភ្លាមៗតាមការស្នើសុំរបស់ធនាគារ ABA ចំពោះកាតណាមួយដែលបានចេញឲ្យអ្នកប្រើប្រាស់កាត។ កាតទាំងអស់មិនអាចធ្វើការផ្ទេរឲ្យអ្នកផ្សេងក្រៅពីបុគ្គលដែលមានឈ្មោះលើកាតនោះឡើយ។

## 8. ភាពមិនប្រក្រតីនៃប្រព័ន្ធ

ធនាគារ ABA មិនអះអាង ឬមិនធ្វើការធានាពាក់ព័ន្ធនឹងប្រតិបត្តិការ មុខងារ ឬសុវត្ថិភាពនៃការប្រើប្រាស់ម៉ាស៊ីន ATM ឬប្រព័ន្ធទូទាត់ ឬឧបករណ៍ណាមួយផ្សេងទៀត (រួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែ ប្រព័ន្ធទូទាត់ណាមួយ (Point-of-Sale-System) ដែលពាក់ព័ន្ធនឹងការដកប្រាក់ ឬការដាក់ប្រាក់ នៃមូលនិធិចូលក្នុង ឬពី គណនីដែលបានកំណត់ ឬប្រតិបត្តិការណាមួយដែលបានធ្វើដោយអ្នកប្រើប្រាស់កាត ក្នុងករណីនីមួយៗ ដោយការប្រើប្រាស់កាត។ ធនាគារ ABA មិនទទួលខុសត្រូវចំពោះការខូចខាត ថ្លៃចំណាយ ការបាត់បង់ ឬការចំណាយណាមួយ (ដោយផ្ទាល់ ឬដោយប្រយោលក្តី) កើតឡើងដោយអ្នកប្រើប្រាស់កាត ដែលជាលទ្ធផល ឬពាក់ព័ន្ធនឹងដំណើរការខុសប្រក្រតីណាមួយ ឬកង្វះប្រតិបត្តិការ មុខងារ ឬសុវត្ថិភាពចំពោះម៉ាស៊ីន ATM ណាមួយ ឧបករណ៍ ឬប្រព័ន្ធទូទាត់។

## 9. ការទទួលខុសត្រូវចំពោះកាតដែលប្រើគ្មានការអនុញ្ញាត បាត់ ឬលួច

អ្នកប្រើប្រាស់កាត ត្រូវជូនដំណឹងមកធនាគារ ABA ភ្លាមៗ (ដោយប្រើមធ្យោបាយមួយក្នុងចំណោមមធ្យោបាយដែលបានរៀបរាប់នៅក្នុងប្រការ ១៩ នៃខ និងលក្ខខណ្ឌនេះ) ហើយធ្វើតាមការណែនាំរបស់ធនាគារ ABA ដើម្បីបញ្ចប់ការប្រើប្រាស់កាត នៅពេលដឹងថាកាតបានបាត់បង់ ត្រូវបានគេលួច ឬប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីអ្នកប្រើប្រាស់កាត។ អ្នកប្រើប្រាស់កាត ត្រូវទទួលខុសត្រូវចំពោះការដកប្រាក់/ប្រតិបត្តិការដែលមិនមានការអនុញ្ញាតណាមួយ និងទាំងអស់ដែលកើតឡើងមុនពេលអ្នកប្រើប្រាស់កាត ជូនដំណឹងដល់ធនាគារ ABA អំពីការបាត់បង់ ការលួច ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ប៉ុន្តែអ្នកប្រើប្រាស់កាត នឹងមិនត្រូវទទួលខុសត្រូវចំពោះការដកប្រាក់/ប្រតិបត្តិការដែលមិនមានការអនុញ្ញាតណាមួយដែលកើតឡើងបន្ទាប់ពីអ្នកប្រើប្រាស់ជូនដំណឹងដល់ធនាគារ ABA អំពីការបាត់បង់ ការលួច ឬការប្រើប្រាស់ដោយគ្មានការអនុញ្ញាត។ ប្រសិនបើកាតដែលបាត់ លួច ឬប្រើប្រាស់មិនត្រឹមត្រូវបាន តាមដានឃើញ និង/ឬប្រគល់មកវិញបន្ទាប់ពីអ្នកប្រើប្រាស់បានរាយការណ៍ អ្នកប្រើប្រាស់កាតមិនត្រូវប្រើកាតនោះម្តងទៀតទេ ហើយធនាគារ ABA នឹងមិនទទួលខុសត្រូវចំពោះប្រតិបត្តិការដកប្រាក់ណាមួយដែលកើតឡើងក្រោយពេលនោះទេ។ កាតដែលរកឃើញត្រូវកាត់បន្ទះម៉ាញ៉េទិចជាពាក់កណ្តាល ដោយអ្នកប្រើប្រាស់កាត ហើយប្រគល់បំណែកទាំងនោះទៅធនាគារ ABA ភ្លាមៗ។

## 10. ការប្រើប្រាស់កាតឥណទាន

ប្រសិនបើកាតឥណទានមានសុពលភាពត្រឹម ៣០ ថ្ងៃមុនថ្ងៃផុតសុពលភាពធនាគារ ABA នឹងជូនដំណឹងដល់អ្នកប្រើប្រាស់កាតដើម្បីស្នើសុំទទួលកាតថ្មី។ ប្រសិនបើអ្នកប្រើប្រាស់កាតមិនស្នើសុំ ទទួលកាតថ្មីក្នុងអំឡុងពេលកំណត់ដោយធនាគារ ABA នោះធនាគារ ABA អាចបិទការប្រើប្រាស់កាតឥណទានដោយមិនជម្រាបជូនដំណឹងជាមុន។

## 11. ការបង្វិលសងវិញ

ធនាគារ ABA មិនទទួលខុសត្រូវចំពោះការយឺតយ៉ាវក្នុងការបង្វិលសងឥណទានវិញទេ ក្រៅពី មូលហេតុកើតចេញពីការមិនបំពេញកាតព្វកិច្ចដោយចេតនា ឬការធ្វេសប្រហែសទាំងស្រុងរបស់ធនាគារ។ ធនាគារ ABA រក្សាសិទ្ធិក្នុងការបង្អាកជាបណ្តោះអាសន្ននូវរាល់ការទូទាត់ដែលបានទទួលដោយអ្នកប្រើប្រាស់កាតពីពាណិជ្ជករដោយវិធីនៃការបង្វិលសងវិញ ដែលទាក់ទងនឹងប្រតិបត្តិការលក់ពីដំបូងក្នុងកាលៈទេសៈណាក៏ដោយ រួមទាំង ប៉ុន្តែមិនកំណត់ត្រឹមតែពេលដែលធនាគារ ABA សង្ស័យថាការទូទាត់ ពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬសកម្មភាពខុសច្បាប់ផ្សេងទៀត។ នៅក្នុងករណីបែបនេះធនាគារ ABA អាចស្នើសុំព័ត៌មានបន្ថែម និងឯកសារពីអ្នកប្រើប្រាស់កាត។ ប្រសិនបើ (i) ធនាគារ ABA កំណត់ (តាមឆន្ទានុសិទ្ធិរបស់ធនាគារ) ថាការទូទាត់មានពាក់ព័ន្ធនឹងការសំអាតប្រាក់ ឬសកម្មភាពខុសច្បាប់ណាមួយផ្សេងទៀត ឬ (ii) អ្នកប្រើប្រាស់កាតមិនគោរពតាមការស្នើសុំណាមួយរបស់ធនាគារ ABA ពាក់ព័ន្ធព័ត៌មាន ឬឯកសារពាក់ព័ន្ធនឹងការទូទាត់នោះ ដោយធនាគារ ABA អាចបង្អាកការទូទាត់នោះជាអចិន្ត្រៃយ៍។

## 12. ការលុបចោលប្រតិបត្តិការ

ប្រសិនបើអ្នកប្រើប្រាស់កាតមានបំណងលុបចោលប្រតិបត្តិការណាមួយ រួមទាំងការកក់ទុក ឬប្រតិបត្តិការដែលកើតឡើងដដែលៗ និង/ឬ កែប្រែកិច្ចព្រមព្រៀងណាមួយដែលបានចុះហត្ថលេខាជាមួយពាណិជ្ជករ អ្នកប្រើប្រាស់កាតត្រូវទាក់ទងពាណិជ្ជករដើម្បីទទួលបានការបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការលុបចោល ឬការធ្វើវិសោធនកម្មនោះ។ ធនាគារ ABA មិនទទួលខុសត្រូវចំពោះចំនួនទឹកប្រាក់ណាមួយនៃប្រតិបត្តិការដែលបន្តទូទាត់ពីគណនីដែលបានកំណត់ បន្ទាប់ពី ពីការលុបចោល ឬវិសោធនកម្មនោះទេ ប៉ុន្តែធនាគារ ABA អាចនឹងប្រមូលចំនួនទឹកប្រាក់នោះ ប្រសិនបើអ្នកប្រើប្រាស់កាតបានធ្វើការលុបចោល ឬកែប្រែប្រតិបត្តិការបានត្រឹមត្រូវជាមួយពាណិជ្ជករ។

## 13. វិវាទ និងថ្លៃដោះស្រាយវិវាទ

ប្រសិនបើអ្នកប្រើប្រាស់កាតស្នើសុំឲ្យធនាគារ ABA ស៊ើបអង្កេតប្រតិបត្តិការដែលមានវិវាទណាមួយ នោះនឹងមានថ្លៃសេវាដំណើរការ ដោយកាត់ប្រាក់ពីគណនីដែលបានកំណត់ នៅពេលមានភស្តុតាងគួរឲ្យជឿជាក់បង្ហាញថា អ្នកប្រើប្រាស់កាតបានចូលរួម ឬអនុញ្ញាតឲ្យធ្វើប្រតិបត្តិការនោះ។ ប៉ុន្តែធនាគារ ABA នឹងជូនដំណឹងដល់អ្នកប្រើប្រាស់កាតជាមុនអំពីថ្លៃសេវាបន្ថែម និងបន្ទុកផ្សេងទៀតដែលមិនមាននៅក្នុងសេវាកម្មរបស់កាត និងកម្រៃជើងសាមុនពេលដំណើរការ។

## 14. ការបរាជ័យក្នុងការបញ្ចប់ដំណើរការប្រតិបត្តិការ

ធនាគារ ABA មិនទទួលខុសត្រូវក្នុងកាលៈទេសៈណាក៏ដោយ ប្រសិនបើធនាគារមិនបានបញ្ចប់ប្រតិបត្តិការពេញលេញលើសំណើទូទាត់ ឬប្រតិបត្តិការរបស់កាត ដែលការខកខានមិនបានបំពេញនោះតម្រូវដោយច្បាប់។ ដោយមិនរាប់ដល់ភាពទូទៅនៃអ្វីដែលបានរៀបរាប់ខាងលើ ធនាគារ ABA មិនត្រូវបានតម្រូវឲ្យបំពេញប្រតិបត្តិការទូទាត់ណាមួយពីគណនីដែលបានកំណត់របស់អ្នកប្រើប្រាស់កាតដែលមិនមានទឹកប្រាក់គ្រប់គ្រាន់នៅក្នុងគណនីនោះ ដើម្បីធ្វើការទូទាត់ប្រតិបត្តិការពាក់ព័ន្ធនោះទេ។

## 15. ការបញ្ចប់ការប្រើប្រាស់កាត

ធនាគារ ABA រក្សាសិទ្ធិបញ្ចប់ ការប្រើប្រាស់កាតរបស់អ្នកប្រើប្រាស់កាតនៅពេលណាក៏បាន ប៉ុន្តែការបញ្ចប់នេះនឹងមិនប៉ះពាល់ដល់ប្រតិបត្តិការបានបញ្ចប់រួចរាល់ ដែលទឹកប្រាក់ទូទាត់ មិនទាន់បានកាត់ចេញពី គណនីដែលបានកំណត់នោះឡើយ។ បន្ទាប់មកចំនួនទឹកប្រាក់ប្រតិបត្តិការ នឹងត្រូវកាត់ចេញដោយផ្ទាល់ដោយធនាគារ ABA ពីគណនីដែលកំណត់នោះ។ អ្នកប្រើប្រាស់កាតអាចបញ្ចប់ការប្រើប្រាស់កាតរបស់ខ្លួនបានគ្រប់ពេលដោយផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ធនាគារ ABA ហើយប្រគល់កាតនោះ ទៅធនាគារវិញដោយកាត់កាតជាពាក់កណ្តាល។ រាល់សំណើទូទាត់ ឬ ប្រតិបត្តិការរបស់កាតដែលបានចាប់ផ្តើមមុនធ្វើនីតិវិធីនេះ ត្រូវបន្តគ្រប់គ្រងដោយ ខ និង លក្ខខណ្ឌ នៃការប្រើប្រាស់កាតនេះ។

## 16. ប្រតិបត្តិការរូបិយប័ណ្ណ

ប្រសិនបើប្រតិបត្តិការរបស់អ្នកប្រើប្រាស់កាតពាក់ព័ន្ធនឹងការបង្វិលសង ឥណទាន ការកែតម្រូវ ឬចំនួនទឹកប្រាក់ទូទាត់ ជារូបិយប័ណ្ណបរទេសក្រៅពីប្រាក់ដុល្លារអាមេរិក នោះ ធនាគារ ABA នឹងប្តូររូបិយប័ណ្ណទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលអាចអនុវត្ត មុនពេលបង្អក កាត់ចេញឬបញ្ចូលក្នុងគណនីដែលបានកំណត់។ អត្រាប្តូរប្រាក់ត្រូវកំណត់ដោយយោងតាម បទប្បញ្ញត្តិប្រតិបត្តិការដែលបង្កើតឡើង

ដោយ សមាគមសេវាវីសាអ៊ិនធើ ណេសិនណល/វីសាគ្លូបិល ម៉ាស្ទ័រវើលវ៉ាយដ៍ យូញៀនផេ អ៊ិនធើណេសិនណល(Visa International Association Service/Visa Global, Master Worldwide, UnionPay International) និងសមាគមកាតផ្សេងទៀត រដ្ឋាភិបាល ឬ ធនាគារ ABA។

## 17. សុវត្ថិភាព

អ្នកប្រើប្រាស់កាតត្រូវការពាររាល់ព័ត៌មាន និងឯកសារទាក់ទងនឹងកាតណាមួយដែលខ្លួនប្រើប្រាស់រួមទាំងប៉ុន្តែមិនកំណត់ត្រឹមតែ លេខរបស់កាត និងលេខកូដរបស់កាត និងមិនត្រូវបញ្ចេញ ឬធ្វើឲ្យលេចចេញ (ទោះជាចេតនា ឬអចេតនាក្តី) ទៅជនដទៃដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីធនាគារ ABA។ នៅពេលដែលអ្នកប្រើប្រាស់លែងត្រូវការប្រើប្រាស់កាត ត្រូវកម្ទេចរាល់ព័ត៌មាន និងឯកសារទាក់ទងនឹងកាតនោះ។ ប៉ុន្តែ ធនាគារ ABA រក្សាសិទ្ធិក្នុងការបញ្ចេញព័ត៌មាន និងឯកសារទាំងនោះតាមតម្រូវការរបស់ច្បាប់។

## 18. សំណង

អ្នកប្រើប្រាស់កាតត្រូវសងសំណង និងទទួលខុសត្រូវ ចំពោះធនាគារ ABA ភ្នាក់ងារ បុគ្គលិក និងនាយក របស់ធនាគារ រាល់ពាក្យបណ្តឹង ឬសំណុំរឿងណាមួយ និងការបាត់បង់ ការទាមទារ ការទទួលខុសត្រូវ ការខូចខាត ការចំណាយ ការពិន័យ ទោស រួមមាន កម្រៃសេវាមេធាវី ដោយផ្ទាល់ ឬដោយប្រយោលក្តីក្រោមហេតុផលកើតចេញពីទំនាក់ទំនងនៃការប្រើប្រាស់ ឬការប្រើប្រាស់មិនត្រឹមត្រូវរបស់អ្នកប្រើប្រាស់កាត ឬការបំពាន ខ និងលក្ខខណ្ឌនេះដោយអ្នកប្រើប្រាស់កាត។

## 19. ការជូនដំណឹងអំពីកាតដែលបាត់

អ្នកប្រើប្រាស់កាតដែលដឹងថាកាតរបស់គាត់បានបាត់ ត្រូវបានគេលួច ឬប្រើប្រាស់ដោយគ្មានការអនុញ្ញាត អាចប្រើមធ្យោបាយណាមួយខាងក្រោមដើម្បីជូនដំណឹងមកធនាគារ ABA ដូចគ្នាដោយអនុលោមតាមប្រការ ៩ នៃ ខ និងលក្ខខណ្ឌទាំងនេះ៖

(i) ទូរស័ព្ទមកមជ្ឈមណ្ឌលទំនាក់ទំនងរបស់ធនាគារ ABA តាមរយៈលេខទូរស័ព្ទ៖ ១ ៨០០ ២០៣ ២០៣ (ដោយឥតគិតថ្លៃ) / (+៨៥៥) ៩៨ ២០៣ ៣៣៣

(ii) បង្កក ឬផ្អាកកាតរបស់អ្នកតាមរយៈកម្មវិធី ABA Mobile ឬ

(iii) អ៊ីមែលមក info@ababank.com និង/ឬ customerservice@ababank.com។

## 20. ហត្ថលេខាលើកាត

អ្នកប្រើប្រាស់កាតត្រូវតែចុះហត្ថលេខាភ្លាមៗនៅលើបន្ទះហត្ថលេខានៅខាងក្រោយកាតដែលចេញឲ្យប្រើប្រាស់នៅពេលទទួលបានកាតដោយផ្ទាល់ពីធនាគារ ABA។

## 21. វិសោធនកម្ម

ធនាគារ ABA អាចធ្វើវិសោធនកម្មលើ ខ និងលក្ខខណ្ឌនៅពេលណាក៏បាន និងពីមួយពេលទៅមួយពេល ដែលធនាគារយល់ថាសមស្រប និងចុះផ្សាយការកែប្រែនោះនៅលើ គេហទំព័ររបស់ធនាគារ។ ការកែប្រែទាំងនោះត្រូវចូលជាធរមានមិនលើសពី៣០ ថ្ងៃក្រោយពីការផ្សព្វផ្សាយនៅលើគេហទំព័ររបស់ធនាគារ។

## 22. ច្បាប់គ្រប់គ្រង

ខ និងលក្ខខណ្ឌការប្រើប្រាស់កាតនេះត្រូវគ្រប់គ្រង និងបកស្រាយស្របតាមច្បាប់នៃប្រទេសកម្ពុជា។

## 23. ដំណោះស្រាយវិវាទ

វិវាទណាមួយដែលកើតឡើង ឬពាក់ព័ន្ធនឹង ខ និងលក្ខខណ្ឌការប្រើប្រាស់កាតនេះ នឹងត្រូវដោះស្រាយជាចុងក្រោយដោយតុលាការ ដែលមានសមត្ថកិច្ចក្នុងប្រទេសកម្ពុជា។

*-ចប់-*